**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងឱកាសប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញា ២០១៩

*សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!*

*សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល!*

*សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី!*

*ឯកឧត្តម លោកជំទាវ ព្រឹទ្ធាចារ្យ លោកតា លោកយាយ!*

*លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់រាប់អាន និងបងប្អូនជនរួមជាតិទាំងអស់ជាទីគោរពស្នេហា !*

ក្នុងឱកាសដ៏មហោឡារិកនៃ **ទិវាអក្ខរកម្មជាតិ ៨ កញ្ញា ២០១៩** នេះ ខ្ញុំព្រះករុណា ខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមសម្តែងនូវក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមចូលរួមប្រកបដោយភាពស្និទ្ធស្នាលជាមួយបងប្អូនជនរួមជាតិ ស្របពេលប្រជាជនកម្ពុជានៅទូទាំងប្រទេសកំពុងរស់នៅក្នុងបរិយាកាសនៃសុខសន្តិភាពនិងការអភិវឌ្ឍ បន្ទាប់ពីរាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភាទទួលបាននូវការទុកចិត្តនិងគាំទ្រពីប្រជាពលរដ្ឋ ឱ្យបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួនជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំឥតរាថយ និងកាន់តែស្វាហាប់ជាងពេលណាៗទាំងអស់ ក្នុងការបម្រើប្រជាពលរដ្ឋក៏ដូចជាក្នុងការពន្លឿនកិច្ចអភិវឌ្ឍ និងជំរុញអនុវត្តកំណែទម្រង់កាន់តែស៊ីជម្រៅនិងទូលំទូលាយលើគ្រប់វិស័យ ឆ្ពោះទៅរកការកសាងអនាគតដ៏រុងរឿងមួយ ស្របតាមឆន្ទៈនិងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងនូវសារលិខិតថ្វាយនិងប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ ជូនជនរួមជាតិ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំព្រមទាំងក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់ អំពីបុព្វហេតុដែលកម្ពុជាត្រូវយកចិត្តទុកដាក់លើការអភិវឌ្ឍធនធានមនុស្ស ដោយសាររាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាជំរុញការលើកកម្ពស់និងការកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់ជូនដល់ស្រទាប់យុវជននូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពព្រមជាមួយនឹងឱកាសទទួលបានការងារធ្វើ ការជួយកសិករក្នុងការអភិវឌ្ឍផលិតកម្មនិងការរកទីផ្សារលក់កសិផល។

កន្លងមកក៏ដូចជាក្នុងពេលបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងបន្តសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍ ដោយផ្ដោតការយកចិត្តទុកដាក់ជាសំខាន់លើការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦នៃរដ្ឋសភា។ ជាក់ស្ដែង ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយក្រសួងមហាផ្ទៃបើកថ្នាក់អក្ខរកម្មនៅតាមមណ្ឌលអប់រំកែប្រែនិងពន្ធនាគារនៅតាមរាជធានី ខេត្ត បានចំនួន ២៥ថ្នាក់ ដែលមានអ្នកជាប់ឃុំឃាំងទទួលបានការរៀនសូត្រសរុប៥៩២នាក់ ក្នុងគោលបំណងផ្ដល់ឱ្យពួកគាត់នូវចំណេះដឹង ជំនាញ មុខរបរ ការចេះអាន ចេះសរសេរ ចេះគិតលេខ និងចេះដោះស្រាយបញ្ហាដែលពាក់ព័ន្ធទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ ពួកគាត់នឹងមានឱកាសរៀនសូត្របន្តលើជំនាញមុខរបរដើម្បីរកប្រាក់ចំណូលបន្ទាប់ពីទទួលបានសិទ្ធិសេរីភាពនិងការធ្វើសមាហរណកម្មទៅក្នុងសង្គមជាតិឡើងវិញ។

ក្រៅពីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយវិស័យឯកជននៅតាមរោងចក្រចំនួន១១ ដោយបានផ្ដល់ឱកាសឱ្យកម្មករ កម្មការិនីរបស់យើង មានលទ្ធភាពចូលសិក្សាក្នុងកម្មវិធីអក្ខរកម្ម ដែលនឹងជួយឱ្យពួកគេអាចបំពេញការងារកាន់តែប្រសើរឡើងថែមទៀត និងជាមូលដ្ឋានគ្រឹះសម្រាប់ស្វែងរកអាជីពការងារដែលមានប្រាក់ចំណូលខ្ពស់ជាងមុន។ម្យ៉ាងវិញទៀត ការចូលសិក្សាក្នុងកម្មវិធីអក្ខរកម្មនេះ ក៏បានផ្ដល់ជាប្រយោជន៍ដល់ម្ចាស់រោងចក្រផងដែរ។

ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាទើបអនុម័តជាផ្លូវការនូវគោលនយោបាយជាតិស្ដីពី**ការសិក្សាពេញមួយជីវិត** ដែលមានគោលបំណង "ផ្ដល់ឱកាសនិងគាំទ្រឱ្យប្រជាជនគ្រប់រូបទទួលបានការសិក្សាគ្រប់រូបភាព និងប្រើប្រាស់ចំណេះដឹងតាមជំនាញដែលទទួលបាន ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ និងប្រាក់ចំណូលស្របតាមយុគសម័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងសង្គមពុទ្ធិ"។ ដើម្បីអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡាត្រូវមានផែនការប្រែក្លាយមជ្ឈមណ្ឌលសិក្សាមួយចំនួនដូចជាមជ្ឈមណ្ឌលសិក្សានៅតាមរោងចក្រនិងមជ្ឈមណ្ឌលអភិវឌ្ឍយុវជន ឱ្យក្លាយទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។ ក្រសួងអប់រំ យុវជន និងកីឡាក៏ត្រូវសហការជាមួយក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈដាក់ឱ្យដំណើរការ "**កម្មវិធីសមមូលកម្រិតអប់រំមូលដ្ឋានតាមប្រព័ន្ធបច្ចេកវិទ្យា**" ដើម្បីផ្ដល់ឱកាសសិក្សាដល់កម្មករទាំងនៅក្នុងនិងក្រៅប្រទេសឱ្យមានលទ្ធភាពបន្តការសិក្សាតាមបែបអនឡាញឬតាមបែបឌីជីថល។

សមិទ្ធផលនៃការអនុវត្តកម្មវិធីអក្ខរកម្មទាំងនេះ បានបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងការចូលរួមគាំទ្រដោយចិត្តស្មោះសពីអ្នកពាក់ព័ន្ធនិងដៃគូអភិវឌ្ឍនានា ជាពិសេសកិច្ចខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ ព្រះសង្ឃ បញ្ញវន្តម្ចាស់រោងចក្រ សហគ្រាស សិស្ស និងនិស្សិតទូទាំងប្រទេស។

នៅឆ្នាំ២០១៩ នេះ **ទិវាអក្ខរកម្មជាតិ ៨ កញ្ញា** ត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ "**អក្ខរកម្មផ្សារភ្ជាប់នឹងជំនាញមុខរបរ**" ដែលមានចក្ខុវិស័យអភិវឌ្ឍប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ឱ្យទទួលបានឱកាសសិក្សាពេញមួយជីវិត គ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់មធ្យោបាយ ប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណសម្បទា ដើម្បីរួមចំណែកបង្កើនសេដ្ឋកិច្ចជាតិនិងសុខដុមជីវិតបុគ្គលនិងសង្គម។ ទស្សនាទាននៃប្រធានបទនៅឆ្នាំនេះ មិនសំដៅត្រឹមតែការរៀនអក្សរ និងលេខនព្វន្តប៉ុណ្ណោះទេ ប៉ុន្តែបានគិតគូរដល់ឱកាស

សម្រាប់យុវជនយើងទទួលបានចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញមុខរបរ និងនវានុវត្តន៍ គ្រប់ផ្នែក គ្រប់វិស័យ ជាពិសេស អក្ខរកម្មបច្ចេកវិទ្យា ដែលសព្វថ្ងៃកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស។

***ជនរួមជាតិជាទីស្នេហា!***

ក្នុងបរិការណ៍នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ និងដើម្បីផ្សារភ្ជាប់ការងារអក្ខរកម្មទៅនឹងជំនាញមុខរបរ ជាពិសេស ឈានទៅសម្រេចបាននូវគោលដៅ ប្រែក្លាយពលករដែលប្រើកម្លាំងសុទ្ធសាធទៅជាពលករដែលមានជំនាញស្របតាម "**យុទ្ធសាស្ត្រកំណើនថ្មី**" របស់កម្ពុជា ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវដល់ស្ថាប័នជាតិ អន្តរជាតិ សហគមន៍ និងពលរដ្ឋគ្រប់រូប សូមយកចិត្តទុកដាក់ខ្ពស់ជាបន្តទៀតដល់ការងារអក្ខរកម្ម ក៏ដូចជាការងារអប់រំទាំងនៅក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ។ ក្នុងស្មារតីនេះ ដើម្បីបន្តចូលរួមលើកកម្ពស់ការងារអក្ខរកម្មនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវដូចតទៅ៖

**ទី១-** ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំគោលនយោបាយ ក្របខណ្ឌច្បាប់ លិខិតបទដ្ឋាន និងយន្តការចាំបាច់ ដើម្បីដឹកនាំ គ្រប់គ្រង និងអនុវត្តឱ្យមានប្រសិទ្ធភាពនិងគុណភាព ដោយធានាបាននូវលទ្ធផលទទួលយកបានក្នុងការផ្តល់ការសិក្សាពេញមួយជីវិតសម្រាប់ប្រជាពលរដ្ឋគ្រប់រូប និងស្របទៅនឹងបរិការណ៍ថ្មីនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

**ទី២-** ក្រសួងស្ថាប័ន គ្រឹះស្ថានសិក្សា មណ្ឌលសិក្សា និងទីវត្តអារាមទាំងអស់ត្រូវបង្កើតកម្មវិធីអប់រំ កម្មវិធីសិក្សាពេញមួយជីវិតទាំងផ្នែកអក្ខរកម្ម ទាំងវិជ្ជាជីវៈឱ្យកាន់តែសម្បូរបែបនិងមានភាពបត់បែនឆ្លើយតបនឹងតម្រូវការអ្នកសិក្សា ដើម្បីផ្តល់សេវាអប់រំពេញមួយជីវិត ទាំងសេវាអប់រំក្នុងប្រព័ន្ធ ទាំងសេវាអប់រំក្រៅប្រព័ន្ធ និងទាំងសេវាអប់រំមិនផ្លូវការដល់ប្រជាពលរដ្ឋគ្រប់រូប។

**ទី៣-** អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវយកចិត្តទុកដាក់ចូលរួមគាំទ្រឱ្យបានខ្លាំងក្លាថែមទៀតក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌលសិក្សានិងជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលមិនបានរៀនសូត្រឬបោះបង់ការសិក្សា ឱ្យមានឱកាសទទួលបានការរៀនសូត្រជាថ្មីតាមថ្នាក់រៀនអប់រំក្រៅប្រព័ន្ធតាមគ្រប់រូបភាព ជាពិសេស ត្រូវខិតខំបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលជាជនមានពិការភាពឱ្យទទួលបានលទ្ធភាពក្នុងការសិក្សារៀនសូត្រ។

**ទី៤-** ប្រព័ន្ធផ្សព្វផ្សាយទាំងអស់រួមមានបណ្តាញទំនាក់ទំនងសង្គមវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី និងព្រឹត្តិបត្រព័ត៌មានរបស់រដ្ឋនិងឯកជន សូមជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីអានុភាពនៃការងារអក្ខរកម្មដល់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយល់ដឹងកាន់តែទូលំទូលាយពោលគឺ "**អក្ខរកម្មផ្សារភ្ជាប់នឹងជំនាញមុខរបរ**"។

**ទី៥-** ក្មួយៗជាសិស្ស និស្សិតតាមគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន ក្រុមយុវជននៃសហភាពសហព័ន្ធយុវជនកម្ពុជា ក្រុមយុវជនកាយរិទ្ធិ និងក្រុមយុវជនកាកបាទក្រហមកម្ពុជា ត្រូវចុះជួយបង្រៀនដោយស្ម័គ្រចិត្តដល់អ្នកមិនចេះអក្សរនៅតាមថ្នាក់អក្ខរកម្មនិងមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលស្ថិតក្នុងមូលដ្ឋានរបស់ខ្លួនកំពុងរស់នៅ។ ដោយឡែក បងប្អូនជនរួមជាតិដែលជាមាតាបិតាឬអ្នកអាណាព្យាបាល ក៏សូមជួយបន្តជំរុញបងប្អូន កូនចៅឱ្យបានចូលរៀនតាមសាលារៀនចំណេះទូទៅ

គ្រប់ៗគ្នា។ ក្មួយៗនិងបងប្អូនដែលពុំទាន់ចេះអក្សរ ភ្លេចអក្សរ ឬបោះបង់ការសិក្សា សូមខិតខំប្រឹងប្រែងស្វែងរកការរៀនសូត្រនៅតាមថ្នាក់អក្ខរកម្ម ថ្នាក់សមមូល ថ្នាក់ចូលរៀនឡើងវិញ និងការបណ្តុះបណ្តាលជំនាញនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលនៅជិតភូមិឋានរបស់ខ្លួន។

**ទី៦-** វត្តអារាមនិងវិហារសាសនា ត្រូវជំរុញចលនាព្រះសង្ឃ បព្វជិតសាសនា តាជី ដូនជី ចូលរួមកម្មវិធីអក្ខរកម្មផ្សារភ្ជាប់នឹងមុខរបរ ឱ្យកាន់តែខ្លាំងក្លាថែមទៀត តាមរយៈការទេសនាអប់រំអំពីសារប្រយោជន៍នៃការរៀនសូត្រ អំពីសីលធម៌និងការលើកកម្ពស់វប្បធម៌រស់នៅក្នុងភាពជាពលរដ្ឋសកល។

**ទី៧-** ដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបង្កើនកិច្ចសហការនិងពង្រឹងភាពជាដៃគូដោយជួយឧបត្ថម្ភគាំទ្រដល់កម្មវិធីអប់រំក្រៅប្រព័ន្ធ ជាពិសេស កម្មវិធីអក្ខរកម្មផ្សារភ្ជាប់នឹងការអប់រំវិជ្ជាជីវៈ ឱ្យមានដំណើរការល្អជាប់ជាប្រចាំ។

**ទី៨-** ប្រធានរោងចក្រ សហគ្រាស និងក្រុមហ៊ុនឯកជន សូមជួយជំរុញការបើកថ្នាក់អក្ខរកម្មគ្រួសារនិងថ្នាក់បំប៉នមុខជំនាញវិជ្ជាជីវៈផ្សេងៗដល់បងប្អូនកម្មករ កម្មការិនី ដើម្បីជាប្រយោជន៍របស់ពួកគេផងនិងជាប្រយោជន៍ដល់ម្ចាស់រោងចក្រ សហគ្រាសផង ដោយយើងទាំងអស់គ្នាត្រូវចងចាំថា **«មានអក្ខរកម្ម មានការគិតគូរនិងការសម្រេចចិត្តបានត្រឹមត្រូវ» «មានអក្ខរកម្មនាំឱ្យការអភិវឌ្ឍសហគមន៍កាន់តែរីកចម្រើន» «មានអក្ខរកម្មមានសុខដុមជីវិតបុគ្គល គ្រួសារ និងសង្គម»។**

ជាថ្មីម្តងទៀត ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សប្បុរសជននានា ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ បព្វជិតសាសនា និងប្រជាពលរដ្ឋទាំងអស់ ដែលបាននិងកំពុងជួយឧបត្ថម្ភគាំទ្រយ៉ាងសកម្មដល់ការងារអក្ខរកម្មនាពេលកន្លងមក។ ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសង្ឃឹមថា ការប្រារព្ធ **ទិវាអក្ខរកម្មជាតិ ៨ កញ្ញា ២០១៩** នឹងបន្តដាស់ស្មារតីយើងទាំងអស់គ្នាឱ្យចូលរួមក្នុងការងារនេះកាន់តែសកម្មថែមទៀត។

ជាទីបញ្ចប់ ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរ និងប្រគេនពរជូន សម្តេចព្រះសង្ឃរាជ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរបងប្អូនជនរួមជាតិ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ ព្រមទាំងក្មួយៗជាទីស្រឡាញ់ទាំងអស់ សូមសមប្រកបដោយពុទ្ធពរបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ ចន្ទ ៤ រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៩

**ហ៊ុន សែន**